ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២៩៨ សហណ ធទឧ

## សេចក្តីជូនដំណឹង

### ស្តីពី ស្ថានភាពអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុរួចមកឃើញថា បច្ចុប្បន្ននេះព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងទទួលរងឥទ្ធិពលខ្យល់មូសុងឦសាន និងជ្រលងសម្ពាធខ្ពស់ពីស៊ីបេរី ។ យោងតាមការព្យាករណ៍ នៅថ្ងៃទី 02 ខែធ្នូ ឆ្នាំ 2014 ខាងមុខនេះ ខ្យល់មូសុងឦសាន និងជ្រលងសម្ពាធខ្ពស់ស៊ីបេរី នឹងបង្កើនឥទ្ធិពលខ្លាំងមកលើតំបន់ភាគខាងជើងប្រទេសកម្ពុជា ។ លក្ខណៈបែបនេះ នឹងធ្វើឱ្យស្ថានភាពធាតុអាកាសនៅព្រះរាជាណាចក្រកម្ពុជា **ចុះត្រជាក់ ចាប់ពីថ្ងៃទី 02 ដល់ថ្ងៃទី 05 ខែធ្នូ ឆ្នាំ 2014** ដោយក្នុងនោះមាន :

- **តំបន់ភ្នំ តំបន់ខ្ពង់រាបភាគខាងជើង និងឦសាន :** រួមមានតំបន់ខ្នងភ្នំដងរែក ខេត្តឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី សីតុណ្ហភាពអប្បបរមា មានពី 13-16 °C, សីតុណ្ហភាពអតិបរមា 25-27 °C ។
- ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន សៀមរាប កំពង់ធំ និងខេត្តស្ទឹងត្រែង សីតុណ្ហភាពអប្បបរមា មានពី 16-19 °C, សីតុណ្ហភាពអតិបរមា មានពី 27-29 °C ។
- រាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ក្រចេះ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ សីតុណ្ហភាពអប្បបរមា មានពី 19-22 °C, សីតុណ្ហភាពអតិបរមា មានពី 28-31 °C ។
- ខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប សីតុណ្ហភាពអប្បបរមា មានពី 22-24 °C, សីតុណ្ហភាពអតិបរមា មានពី 32-34 °C ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន **ជាពិសេសចំពោះវិរៈកងទ័ពដែលកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ** សូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ចំពោះស្ថានភាពអាកាសធាតុ ដែលចុះត្រជាក់នេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh